# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

**ការបំពាក់មេដាយ The Order of the Sacred Treasure, Silver Rays**

**ជូនចំពោះ លោកស្រី ជា ច័ន្ទណាត្រី**
**អតីតបុគ្គលិកនៃស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា**

ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៦

ពិធីបំពាក់មេដាយ ជូនចំពោះលោកស្រី **ជា ច័ន្ទណាត្រី** អតីតបុគ្គលិកស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា បានប្រព្រឹត្តិទៅនៅថ្ងៃទី១៦ ខែសីហា នៅនិវេសនដ្ឋានឯកឧត្តមឯកអគ្គរាជទូតជប៉ុនប្រចាំប្រទេសកម្ពុជា។

នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ រដ្ឋាភិបាលជប៉ុនបានប្រកាសអំពីការប្រគល់មេដាយនិទាឃរដូវឆ្នាំ២០១៦សម្រាប់ជនបរទេស ជូនលោកស្រី **ជា ច័ន្ទណាត្រី** ដែលជាជនបរទេស១រូបក្នុងចំណោមជនបរទេសទាំង៩១រូប ហើយលោកស្រីទទួលបានមេដាយ **The Order of the Sacred Treasure, Silver Rays** ជាការទទួលស្គាល់នូវការរួមចំណែករបស់លោកស្រីក្នុងសកម្មភាពនានារបស់ស្ថានទូតជប៉ុននៅប្រទេសកម្ពុជា។

បន្ទាប់ពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១មក ស្ថានទូតជប៉ុនបានចាប់ផ្តើមធ្វើសកម្មភាពរបស់ខ្លួនឡើងវិញនៅទីក្រុងភ្នំពេញនៅឆ្នាំ១៩៩២។ បន្ទាប់ពីបានបម្រើការងារជាមន្ត្រីការទូតនៅក្រសួងការបរទេសកម្ពុជាមក លោកស្រី **ជា ច័ន្ទណាត្រី** បានចាប់ផ្តើមធ្វើការនៅស្ថានទូតជប៉ុនតាំងតែពីការចាប់ផ្តើមបើកស្ថានទូតជប៉ុនឡើងវិញ។ លោកស្រីបានរួមចំណែកដ៏គួរអោយកត់សំគាល់ក្នុងសកម្មភាពសំខាន់ៗរបស់ស្ថានទូតជប៉ុនអស់រយៈពេល២៣ឆ្នាំ និង៨ខែ។